# ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៦០២

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/ ៥៧៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីការកំណត់ការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ១៣៧ គជប.សសរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីបេក្ខជនជាប់ឆ្នោតក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ក្នុងអាណត្តិទី១ ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- ឯកឧត្តម យឹម សុខុម | ជាប្រធានក្រុមប្រឹក្សាខេត្ត |
| ២- ឯកឧត្តម សុខ ឌីន | ជាសមាជិកក្រុមប្រឹក្សាខេត្ត |
| ៣- ឯកឧត្តម នុង សេង | ជាសមាជិកក្រុមប្រឹក្សាខេត្ត |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៤- ឯកឧត្តម លុយ ឡាំ ជាសមាជិកក្រុមប្រឹក្សាខេត្ត
៥- ឯកឧត្តម ណុប អឿន ជាសមាជិកក្រុមប្រឹក្សាខេត្ត
៦- ឯកឧត្តម អ៊ុច សំអឿន ជាសមាជិកក្រុមប្រឹក្សាខេត្ត
៧- ឯកឧត្តម សុខ យ៉ាន ជាសមាជិកក្រុមប្រឹក្សាខេត្ត
៨- ឯកឧត្តម ម៉ុក ស៊ន ជាសមាជិកក្រុមប្រឹក្សាខេត្ត
៩- ឯកឧត្តម ហួត ថន ជាសមាជិកក្រុមប្រឹក្សាខេត្ត
១០- ឯកឧត្តម ឆេស លន់ ជាសមាជិកក្រុមប្រឹក្សាខេត្ត
១១- លោកជំទាវ កែវ សុខុម ជាសមាជិកក្រុមប្រឹក្សាខេត្ត
១២- ឯកឧត្តម ចាស ឌឹម ជាសមាជិកក្រុមប្រឹក្សាខេត្ត
១៣- ឯកឧត្តម ស៊ុំ ប៊ុនធឿន ជាសមាជិកក្រុមប្រឹក្សាខេត្ត
១៤- ឯកឧត្តម ឡៅ សឿន ជាសមាជិកក្រុមប្រឹក្សាខេត្ត
១៥- ឯកឧត្តម ម៉ក់ ស៊ីណាទុង ជាសមាជិកក្រុមប្រឹក្សាខេត្ត
១៦- ឯកឧត្តម ស៊ីន្ហ ស៊ិន ជាសមាជិកក្រុមប្រឹក្សាខេត្ត
១៧- ឯកឧត្តម ពយ សារិទ្ធ ជាសមាជិកក្រុមប្រឹក្សាខេត្ត ។

**មាត្រា ២ :** ក្នុងករណីមានសមាជិកក្រុមប្រឹក្សាណាម្នាក់ បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា២២ និងមាត្រា២៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៣ :** ក្នុងការអនុវត្តការងារ ប្រធាន និងសមាជិកក្រុមប្រឹក្សាខេត្តកំពង់ស្ពឺ ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាន ។

**មាត្រា ៤ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល.០៩០៥.៦០៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩

លេខ : ៥៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ជិនកេន